# សិក្ខាសាលាស្តីអំពី "យុវជនជនបទ និងការអភិវឌ្ឍមូលដ្ឋាន" ជាមួយក្រុមអ្នកកាសែតកម្ពុជា

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ដោយមានការឧបត្ថម្ភថវិកាពីមូលនិធិ ហ្វ្រីឌ្រិច-ណៅម៉ាន់ ដើម្បីសេរីភាព នៃប្រទេសអាល្លឺម៉ង់ បានរៀបចំ សិក្ខាសាលាមួយជាមួយក្រុមអ្នកសារព័ត៌មានប្រទេសកម្ពុជាស្តីអំពី " យុវជនជនបទ និងការអភិវឌ្ឍមូលដ្ឋាន " នៅថ្ងៃទី ០៣-០៤ ខែកក្កដា ឆ្នាំ ២០១០ នៅសណ្ឋាគារខ្សាច់មាស ខេត្តព្រះសីហនុ។ គោលបំណងសំខាន់របស់សិក្ខាសាលាគឺ ដើម្បីចែករំលែកនូវបទពិសោធន៍ទាក់ទងទៅនឹងស្ថានភាព របស់យុវជននៅជនបទ និងការងារមួយចំនួន ក្នុងការលើកកម្ពស់ស្ថានភាពយុវជនជនបទ និងការអភិវឌ្ឍ សហគមន៍របស់ពួកគេ។
តំណាងសិស្សយុវសហគ្រិនកសិកម្មវ័យក្មេងចំនួន ៤ នាក់ និងអ្នកសារព័ត៌មានចំនួន ៤០ នាក់ ដែលជាតំណាងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយចំនួន ២១ នៅប្រទេសកម្ពុជា រួមមាន វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី និងកាសែតជាតិ និងអន្តរជាតិ បានចូលរួមសិក្ខាសាលានេះ។

លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាក និងលោក យឹម សុផាណ្ណា អ្នកគ្រប់គ្រងកម្មវិធីនៃមូលនិធិ ហ្វ្រីឌ្រិច-ណៅម៉ាន់ ដើម្បីសេរីភាពប្រចាំនៅកម្ពុជា ធ្វើការសម្របសម្រួល និងបានចែករំលែកផងដែរអំពីសកម្មភាព និងការរីកចម្រើនរបស់ក្រុមសន្សំប្រាក់យុវជន និងសមាគមន៍សន្សំប្រាក់គ្រូបង្រៀន។ លោកបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការ សេដាកមានប្រសាសន៍ថា "កំណើនចំនួនយុវជនមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំពោលគឺពី ៣សែននាក់ទៅ ៤សែននាក់ក្នុងមួយឆ្នាំដែលជាកំលាំង និងធនធានមនុស្សយ៉ាងសំខាន់ នៅក្នុងការងារអភិវឌ្ឍន៍មូលដ្ឋានជនបទ ក៏ដូចជាប្រទេសជាតិទាំងមូល"។ លោកបណ្ឌិតបន្តថា តាមការស្ទង់មតិមួយឱ្យដឹងថា នៅក្នុងចំណោមសិស្សជាយុវជន ដែលរៀននៅវិទ្យាល័យ មានសិស្សចំនួន ២៥% ចង់រៀនជំនាញកសិកម្ម។ លោកថា សេដាកកំពុងតែរៀបចំឱ្យមានប្រព័ន្ធអប់រំមួយលើជំនាញកសិកម្មជាលក្ខណៈអាជីពច្បាស់លាស់ នៅតាមវិទ្យាល័យ ដែលនឹងធ្វើការសាកល្បងបង្រៀននៅតាមវិទ្យាល័យមួយចំនួននៅពេលខាងមុខ។

តំណាងយុវជនជនបទ និងជាសិស្សកម្មវិធីយុវសហគ្រិនកសិកម្មវ័យក្មេងចំនួន ៤នាក់មកពីខេត្តកំពង់ឆ្នាំង ស្វាយរៀង និងខេត្តកំពត បានធ្វើការចែករំលែកផងដែរនូវបទពិសោធន៍ក្នុងការអភិវឌ្ឍន៍ខ្លួនឯង និងអភិវឌ្ឍសហគមន៍របស់ពួកគាត់ នៅពេលមុន និងក្រោយពេលចូលរៀនជាមួយ សេដាក ដែលរួមមានការរីកចំរើនទាំងចំណេះដឹងបច្ចេកទេសកសិកម្ម សុខភាព និងប្រាក់ចំណូលកើនឡើង ជាដើម ។ល។

ជាលទ្ធផល អ្នកចូលរួមទាំងអស់ ពិសេសអ្នកសារព័ត៌មានបានស្វែងយល់កាន់តែច្បាស់បន្ថែមទៀតអំពីស្ថានភាពរបស់យុវជននៅតាមជនបទ ដែលរួមមានទាំងបញ្ហាប្រឈម និងសេចក្តីត្រូវការក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគាត់ ដែលអ្នកសារព័ត៌មាន

បានប្តេជ្ញាចូលរួមចំណែកជួយធ្វើការផ្សព្វផ្សាយអោយកាន់តែទូលំទូលាយថែមទៀត ដើម្បីជួយដល់យុវជនជនបទទទួលបានចំណេះដឹង និងជំនាញអាជីពពិតប្រាកដ ដើម្បីអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគាត់។ លើសពីនេះទៅទៀត ក្រុមអ្នកសារព័ត៌មានក៏បានបោះឆ្នោត បង្កើតសមាគមសន្សំប្រាក់អ្នកសារព័ត៌មានកម្ពុជាជាផ្លូវការ លើកដំបូងនៅប្រទេសកម្ពុជា ដោយមានការបោះឆ្នោតជ្រើសតាំងប្រធាន និងគណៈកម្មាធិការគ្រប់គ្រងផងដែរ។ មកដល់ពេលនេះសមាគមសន្សំប្រាក់អ្នកសារព័ត៌មានកម្ពុជាមានសមាជិកសរុបទាំងចំនួន ២៤ នាក់។

សេដាក បានធ្វើការគាំទ្រដល់យុវជនជនបទចាប់តាំងពីចុងឆ្នាំ ២០០៦ ដោយផ្តល់ឱកាសដល់ យុវជនដែលប្រឡងជាប់/ធ្លាក់បាក់ឌុបចុះរៀនសូត្រជាមួយគម្រោងសេដាក ហើយនៅដើមឆ្នាំ ២០០៨ ដោយមានការគាំទ្រពីសប្បុរសជនជនជាតិ ជប៉ុន កម្មវិធីអាហាររូបករណ៍ **ESP** នៃប្រទេសអាល្លឺម៉ង់ និងអង្គការហៃក សេដាក រៀបចំឱ្យមានជាកម្មវិធី សិស្សយុវសហគ្រិនកសិកម្ម ដែលបច្ចុប្បន្ន បាននិងកំពុងធ្វើការនៅខេត្តជាក់លាក់ចំនួន ៧ រួមមាន (កំពត, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម ស្វាយរៀង, និង ព្រៃវែង ដែលមានសិស្សសរុបចំនួន ២១៧ នាក់ (ស្ត្រី ៨៤នាក់)។

គួរជំរាបជូនថា ដោយមានការឧបត្ថម្ភថវិកាពីមូលនិធិ ហ្វ្រីឌ្រិច-ណៅម៉ាន់ ដើម្បីសេរីភាព នៃប្រទេសអាល្លឺម៉ង់ នេះគឺជាលើកទី ៣ ហើយ ដែលសេដាកបានរៀបចំ សិក្ខាសាលាជាមួយក្រុមអ្នកសារព័ត៌ ដើម្បីបង្កើនការយល់ដឹង និងជំរុញការងារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទឱ្យកាន់តែមានភាពប្រសើរឡើង។

